**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ២៣
ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩
**<u>សាលដីកា</u>**
លេខៈ ១០៧
ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី២៨
ខែកក្កដា ឆ្នាំ១៩៩៨ ដោយមានសមាសភាពដូចតទៅៈ
១.ឯកឧត្តម ............ ជាប្រធាន
២.លោក ............ ជាចៅក្រមរបាយការណ៍
៣.លោក ............ ជាចៅក្រម
៤.លោក ............. ជាចៅក្រម
៥.លោក ............ ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-កញ្ញា .................

**<u>តំណាងមហាអយ្យការ</u>**

-លោក ............. ជាអគ្គព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ៧៥៨ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៣៥ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ រវាងៈ

ម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ហសភេទស្រី អាយុ៥២ឆ្នាំមុខរបរពាណិជ្ជករទីលំនៅផ្ទះលេខ៨៦$E_0$ ផ្លូវលេខ ១៤៨ សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញក្រុងភ្នំពេញ។ឪពុកឈ្មោះហាក់ អូន(ស)ម្តាយឈ្មោះប៊ុន យ៉ុង(ស) ។

និងចុងចម្លើយបណ្តឹងសាទុក្ខឈ្មោះមខអាយុ៤២ឆ្នាំ ជាតិខ្មែរ ទីលំនៅផ្ទះលេខ១២៨សេ ផ្លូវប៉ាស្ទ័រ សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

មានមេធាវីលោក ...........

**<u>កម្មវត្ថុបណ្តឹងៈ</u>** ប្តឹងទាមទារប្រាក់

តាមបណ្តឹងសាទុក្ខលេខ ៤៣២ ចុះថ្ងៃទី១៧ ខែធ្នូឆ្នាំ១៩៩៨ របស់អ្នកស្រី ហសបានប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ៧៥៨ ចុះថ្ងៃទី០៣ ខែធ្នូឆ្នាំ១៩៩៨ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៧ របស់លោក មខជាដើមចោទថាលោកស្រី ហសបានខ្ចីប្រាក់ពីខ្លួនតាំងពីខែ០៦ ឆ្នាំ១៩៩៦ បន្តបន្ទាប់សរុប ៤៥ម៉ឺនដុល្លាអាមេរិក ហើយសន្យាសងមកខ្លួនគ្រប់ចំនួនវិញមិនឲ្យហួសពីខែ១២ ឆ្នាំ១៩៩៦ ឡើយ ប៉ុន្តែរហូតមកដល់ពេលនេះឈ្មោះ ហាក់ ស្រ៊ាងនៅតែពុំព្រមសងប្រាក់ខ្លួនដដែល ។

តាមពាក្យបណ្ដឹងតបចុះថ្ងៃទី២៤-០៤-៩៨ របស់ឈ្មោះហសជាចុងចម្លើយថាចំពោះលោក មុត ខៀវដែលថាខ្លួនជំពាក់ប្រាក់៤៥ម៉ឺនដុល្លាអាមេរិកនោះពុំពិតទេ ព្រោះខ្លួនពុំដែលខ្ចីប្រាក់លោក មខឡើយ ។ ឯកិច្ចសន្យាដែលខ្លួនបានធ្វើជាមួយលោកមខនោះគឺជាកិច្ចសន្យាដូរអាជ្ញាប័ណ្ណឈើចំនួន៤៩.៩១៧ ម៉ែត្រគូបដែលលោក មខត្រូវបំពេញឲ្យខ្លួន តែលោក មខពុំបានឲ្យអាជ្ញាប័ណ្ណឈើមកខ្លួនឡើយ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ ០៧ប្រក ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៩៧ របស់តុលាការក្រុងភ្នំពេញដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៧ របស់ដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ហាមឃាត់អ្នកស្រីហាក់ស្រ៊ាងមិនឲ្យលក់ផ្ទេរសិទ្ធិដូលឬធ្វើអំណោយទៅអ្នកដ៏ទៃនូវផ្ទះលេខ៨៦$E_0E_1E_2E_3$ ផ្លូវលេខ១៤៨ សង្កាត់ផ្សារកណ្ដាល២ ខណ្ឌដូនពេញ ក្រុងភ្នំពេញ ដីឡូត៍លេខ ១១ ផ្លូវលេខ ៤៥ សង្កាត់បឹងកក់២ និងដីឡូត៍លេខ១៣ ក្រុម១២ សង្កាត់បឹងកក់១ ខណ្ឌទួលគោក ក្រុងភ្នំពេញ ជាបណ្ដោះអាសន្នសិន រងចាំតុលាការសម្រេចដល់អង្គេតសេចក្ដី ។

៣-បង្គាប់ឲ្យដើមចោទបង់ប្រាក់ប្រដាប់ក្ដីគឺ:ពន្ធចុះបញ្ជីក្ដីនិងហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ សរុប២០០០៛ ប្រាក់នេះបានកាត់យកពីប្រាក់២០០០៛ ដែលដើមចោទបានបង់ទុករួចជាស្រេចតាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ។

៤-ដីកានេះមានអនុភាពអនុវត្តភ្លាមៗ ទោះបីជាមានបណ្ដឹងឧទ្ធរណ៍ក៏ដោយ ។

បានឃើញសាលក្រមលេខ ៦០(ក) ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញបានសម្រេចចំពោះមុខគូភាគីដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ:

១-ទទួលពាក្យបណ្ដឹងរបស់ឈ្មោះ មខចុះថ្ងៃទី២៧-០៤-៩៧ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-ទទួលលិខិតប្រគល់សិទ្ធិរបស់ឈ្មោះ មខឲ្យទៅឈ្មោះ នេត វណ្ណ ជាតំណាងមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៣-ទទួលពាក្យបណ្ដឹងតបរបស់ចុងចម្លើយឈ្មោះ ហសចុះថ្ងៃទី២៤-៤-៩៨ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៤-ទុកជាមោឃ:កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១០-០៥-៩៦ ,២០-០៦-៩៦ ,២០-០៦-៩៦ និងចុះថ្ងៃទី០៤-០៧-៩៦ រវាងហសនិងមខចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ តាមមាត្រា៥នៃក្រឹត្យច្បាប់លេខ ៣៨ ចុះថ្ងៃទី២៨-១០-១៩៨៨ ។

៥-បង្គាបឲ្យដើមចោទឈ្មោះមខសងប្រាក់ចំនួន០៦ម៉ឺនដុល្លាអាមេរិក ព្រមទាំងជម្ងឺចិត្តចំនួន១ម៉ឺនដុល្លាអាមេរិក ឲ្យទៅចុងចម្លើយឈ្មោះហសវិញ ។ សំណូមពរលើសពីនេះបដិសេធចោល ។

៦-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន៧០០០៛ គឺពន្ធចុះបញ្ជីក្ដីនិងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ រង្វាន់សាក្សី៣០០០៛ និងអ្នកប្រគល់ដីកាកោះ២០០០៛ ពីដើមចោទឈ្មោះ មខ។

៧-បង្គាប់ឲ្យដើមចោទឈ្មោះមខបង់ប្រាក់ប្រដាប់ក្ដីចំនួន ៧០០០៛ គឺពន្ធចុះបញ្ជីក្ដីនិងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន២០០៛ រង្វាន់សាក្សី៣០០០៛ និងអ្នកប្រគល់ដីកាកោះ២០០០៛ ប្រាក់នេះត្រូវ

កាត់យកពីប្រាក់៧០០០៛ ដែលចុងចម្លើយបានបង់រួចជាស្រេច កាលបើហួសឧទ្ធរណ៍បង្គាប់ឲ្យដើមចោទសង់ប្រាក់ ៧០០០៛ ទៅឲ្យចុងចម្លើយវិញ និងឲ្យបង់ពន្ធសមាមាត្រ១%លើទឹកប្រាក់ចំនួន០៦ម៉ឺនដុល្លាអាមេរិក និងជម្ងឺចិត្ត ចំនួន ១ម៉ឺនដុល្លាអាមេរិក ប្រាក់នេះត្រូវបង់ចូលថវិការដ្ឋចំនួន៨០% និងរង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៨-សាលក្រមនេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគូភាគីសម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់ ចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៤៥ ចុះថ្ងៃទី០៦ខែមិថុនា ឆ្នាំ១៩៩៨ របស់ឈ្មោះនេត វណ្ណៈ តំណាងឲ្យឈ្មោះមខដែលប្ដឹងជំទាស់នឹងសាលដីការដ្ឋប្បវេណីលេខ ៦០(ក)ចុះថ្ងៃទី០៣ខែមិថុនា ឆ្នាំ១៩៩៨ របស់តុលាការក្រុងភ្នំពេញនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ៤៣៣ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍សម្រេចចំពោះមុខលោក អ៊ិត សារិន តំណាងឲ្យដើមចោទ កំបាំងមុខចុងចម្លើយឈ្មោះហសដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្ដឹងរបស់លោក នេត វណ្ណៈ តំណាងឲ្យលោក មខជាដើមចោទទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៨ ដែលលោកមខផ្ទេរសិទ្ធិតវ៉ានៅសាលាឧទ្ធរណ៍ជូនលោក អ៊ិត សារិន ទុកជាត្រឹមត្រូវតាមទម្រង់និងគតិច្បាប់

៣-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ៦០(ក) ចុះថ្ងៃទី០៣-០៦-៩៨ របស់តុលាការក្រុងភ្នំពេញចោលជាអសារបង់ ។

៤-បង្គាប់ឲ្យអ្នកស្រី ហសសងប្រាក់ចំនួន៤៥០.០០០ដុល្លា ទៅឲ្យលោកមខតាមកិច្ចសន្យា ។

ករណីគ្មានប្រាក់សងត្រូវរឹបអូសទ្រព្យសម្បត្តិលក់ឡាយឡុងហើយបើរឹងរុះត្រូវដាក់គុកបង្ខំរូបកាយដើម្បីទារសំណង ។

៥-រឹបអូសប្រាក់ប្រដាប់ក្ដីនៅជាន់សាលាឧទ្ធរណ៍ដែលដើមបណ្ដឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធហ្នឹងនិងពន្ធចុះបញ្ជីក្ដី១៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកិច្ចប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥០០០៛ សរុប១៣០០០៛ ។

កាលបើផុតកំណត់ប្ដឹងសាទុក្ខ បង្គាប់ឲ្យអ្នកស្រីហសសងប្រាក់១៣០០០៛ ទៅលោកមខវិញ និងឲ្យអ្នកស្រីហសបង់ពន្ធសមាមាត្រ១%លើចំនួនទឹកប្រាក់៤៥ម៉ឺនដុល្លាអាមេរិក ។ប្រាក់នេះ២០%ត្រូវបានជារង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស និង៨០%ត្រូវបានជាប្រយោជន៍ថវិកាជាតិ ។

៦-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខលោកអ៊ិត សារិន តំណាងឲ្យដើមចោទ កំបាំងមុខចុងចម្លើយឈ្មោះហសសម្រេចបើកផ្លូវប្ដឹងទាស់និងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងទាស់លេខ ៤២ចុះថ្ងៃទី២៤ ខែសីហាឆ្នាំ១៩៩៨ របស់ឈ្មោះហសបានប្ដឹងទាស់នឹងសាលដីកាលេខ ៤៣៣ ចុះថ្ងៃទី១៣ខែសីហា ឆ្នាំ១៩៩៨ នៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីកាលេខ ៧៤៨ ចុះថ្ងៃទី០៣ខែធ្នូឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍បានសម្រេចចំពោះមុខគូក្ដីដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងទាស់ចុះថ្ងៃទី២៤ ខែសីហាឆ្នាំ១៩៩៨ របស់ឈ្មោះហសទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលដីកាកំបាំងមុខលេខ ៤៣៣ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

៣-សាលដីកានេះជំនុំជំរះនិងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ៤៣២ ចុះថ្ងៃទី១៧ខែធ្នូឆ្នាំ១៩៩៨ របស់ហសបានប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនៃសាលដីកាលេខ ៧៥៨ ចុះថ្ងៃទី០៣ខែធ្នូ ឆ្នាំ១៩៩៨ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី១០ ខែកុម្ភៈឆ្នាំ១៩៩៩ របស់អ្នកស្រីហស។

បានឃើញសារណាតបចុះថ្ងៃទី២៣ខែមិនា ឆ្នាំ១៩៩៩ របស់លោកមខ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថាៈសាលដីការដ្ឋប្បវេណីលេខ៧៥៨ ចុះថ្ងៃទី០៣ខែធ្នូ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងខាងគតិច្បាប់ហើយ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់អ្នកស្រីហាក់ ស្រ៊ាងជាចុងចម្លើយ និងជាដើមបណ្តឹងសាទុក្ខដែលបានឆ្លើយនៅពេលសវនាការថាៈ ខ្លួនមិនសុខចិត្តព្រោះសាលាឧទ្ធរណ៍កាត់ឲ្យខ្លួនមិនយុត្តិធម៌ ហើយស្រាវជ្រាវរឿងខ្លួនមិនច្បាស់លាស់ខ្លួនមិនបានខ្ចីលុយលោក មខទេសូម្បីតែមុខខ្លួនមិនស្គាល់ផង ។ខ្លួនរត់ការគឺខ្លួនពឹងលោក អ៊ឹង ផល្លា និងឈ្មោះហួរស្រេង តែប៉ុណ្ណោះ ។ ហើយខ្លួនបានប្រគល់លុយឲ្យគាត់មួយរយៈហើយ ហើយអាដ្ឋាប័ណ្ណនេះគេបានដកយកហើយ ។

ក្រឡាបញ្ជីឡើងអានសារណាតបរបស់លោក មខ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក ........... ជាមេធាវីការពារឲ្យដើមចោទ និងចុងចម្លើយសាទុក្ខ នៅពេលសវនាការថាៈ ប្រាក់ទាំងអស់ដែលអ្នកស្រី ហសខ្ចីនោះគឺពុំគោរពតាមការកំណត់នៃការសងប្រាក់ដែលមានចែងនៅក្នុងកិច្ចសន្យាទេ ។លុះដល់ថ្ងៃទី០៤-០៩-៩៦ អ្នកស្រីហសបានធ្វើកិច្ចសន្យាចំនួនពីរច្បាប់បញ្ជាក់ថាៈ ចំពោះកិច្ចសន្យាជំពាក់ប្រាក់ចាស់ឥឡូវនេះខ្លួនសុំដាក់ជូនប្លង់ផ្ទះចំនួនពីរ និងមូលប្បទានបត្រលេខ ០៥២៩៥២៩ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ១៩៩៦ មានទឹកប្រាក់ចំនួន ប្រាំលានបាទ ថៃ ហើយសន្យាសងជាសាច់ប្រាក់ដុល្លាអាមេរិកជាដំណាក់ៗចាប់ពីថ្ងៃទី១៦ខែវិច្ឆិកា មិនឲ្យលុយខែ១២ឆ្នាំ១៩៩៦ ។ហើយការលើកឡើងរបស់អ្នកស្រីហសគឺមិនពិតទេ ។ហេតុនេះសុំតុលាការពិចារណា និងតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រីហសសារណារបស់លោក មខនឹងសេចក្តីសន្និដ្ឋានរបស់មេធាវីដើមចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថាៈ បណ្តឹងសាទុក្ខលេខ ៤៣២ ចុះថ្ងៃទី១៧ខែធ្នូឆ្នាំ១៩៩៨ របស់អ្នកស្រីហាសធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថាៈ តាមលិខិតចុះថ្ងៃទី០៧-០៦-៩៦,១៨-០៦-៩៦,១៦-១០-៩៦ និងលិខិតចុះថ្ងៃទី១៣-១១-៩៦ ថា អ្នកស្រីហាសបានប្រគល់ប្រាក់ចំនួន ០៦ម៉ឺនដុល្លាអាមេរិក ឲ្យលោកហួរ ស្រេង និងលោកអ៊ឹង ផល្លា យកទៅជូនលោកមខក្នុងការរត់អាជ្ញាបណ្ណនាំឈើ ដែលគប្បីតុលាការកំពូលពិចារណា ។

-យល់ឃើញថាៈ ការដែលសាលាឧទ្ធរណ៍យល់ថាកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី១០-០៥-៩៦ ,២០-០៦-៩៦ និង កិច្ចសន្យាចុះថ្ងៃទី២០-០៦-៩៦ ពិតជាកិច្ចសន្យាខ្ចីប្រាក់យ៉ាងពិតប្រាកដ ពុំមែនជាកិច្ចសន្យាដែលធ្វើឡើងដើម្បីឲ្យជឿទុកចិត្តក្នុងការធ្វើអាជ្ញាប័ណ្ណនោះ ជាការភ័ន្តច្រឡំ ពីព្រោះថាកិច្ចសន្យាខ្ចីប្រាក់រវាងអ្នកស្រីហាក់ ស្រ៊ាង និង លោក មខចំនួន៤៥ម៉ឺនដុល្លាអាមេរិកនោះ គឺពុំមានលិខិតណាមួយដែលបញ្ជាក់ថាអ្នកស្រី ហាសនិងមខបានទទួល ឬប្រគល់សាច់ប្រាក់តាមចំនួននោះឡើយ គឺគ្រាន់តែជារូបភាពខ្ចីជំពាក់មួយដែលធ្វើឡើងក្នុងគោលបំណងឲ្យភាគីអ្នកទទួលធ្វើការងារសុំអាជ្ញាប័ណ្ណឈើនាំចេញឲ្យខ្លួនមានជំនឿទុកចិត្តតែប៉ុណ្ណោះ ។ដែលតាមមាត្រា៥នៃក្រឹត្យច្បាប់លេខ៣៨ក្រច ចុះថ្ងៃទី២៨-១០-៨៨ កិច្ចសន្យាទាំងនោះត្រូវជាមោឃៈដាច់ខាត ។ពីព្រោះការឲ្យខ្ចីប្រាក់ដ៏ច្រើនដោយពុំមានគុណប្រយោជន៍ពុំមានការប្រាក់ និងពុំមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរណាមួយ នោះពុំអាចឲ្យជឿបានឡើយ ។

-យល់ឃើញថាៈកិច្ចសន្យាខ្ចីប្រាក់ទាំងបីលើករវាងអ្នកស្រីហាសនឹងលោកមខពុំមានលក្ខណៈគួរឲ្យតុលាការជឿបានឡើយពីព្រោះជាកិច្ចសន្យាទី១ធ្វើនៅថ្ងៃទី១០-០៥-៩៦ ហើយត្រូវសងនៅថ្ងៃទី១០-០៦-៩៦ ប៉ុន្តែកិច្ចសន្យានេះអ្នកខ្ចីពុំទាន់បានសងតាមកិច្ចសន្យាផង ម្ចាស់បំណុលបែរជាឲ្យខ្ចីលើទី២ និងលើកទី៣នៅថ្ងៃទី១ថែមទៀត ហើយសាក្សីដឹងឮគឺលោកអ៊ឹង ផល្លា ដែលជាអ្នកទទួលប្រាក់ពីអ្នកស្រី ហាសថាយកទៅជូនលោក មខថែមទៀត ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍យល់ថា បើអ្នកស្រីហាសបានជួលលោក មខឲ្យរត់ការធ្វើអាជ្ញាប័ណ្ណនាំឈើចេញទៅក្រៅប្រទេសពិតមែននោះហើយលោកមខមិនបានប្រគល់អាជ្ញាប័ណ្ណនាំឈើចេញទៅឲ្យអ្នកស្រីហាសមែននោះប្រាកដជាអ្នកស្រីហាសមិននៅស្ងាត់ស្ងៀម និងអូបន្លាយពេលរហូតដល់ផុតកំណត់ប្តឹងមោឃៈភាពកិច្ចសន្យានោះទេ ក៏ជាការភ័ន្តច្រឡំដែរ ពីព្រោះថាតាមមាត្រា១៨ នៃក្រឹត្យច្បាប់លេខ ៣៨ក្រច ចុះថ្ងៃទី២៨ខែតុលា ឆ្នាំ១៩៨៨ បានចែងថាជនគ្រប់រូបអាចនឹងសុំមោឃៈភាពដាច់ខាតនៃកិច្ចសន្យា ដែលមានចែងក្នុងមាត្រា៥ បានគ្រប់ពេលវេលា ។ដូច្នេះការដែលអ្នកស្រីហាសនៅស្ងាត់ស្ងៀមពុំមែនបានន័យថាអ្នកស្រីបានទទួលអាជ្ញាប័ណ្ណពីលោកមខហើយនោះទេ ។

ម្យ៉ាងទៀតតាមចម្លើយរបស់អ្នកស្រីហាសនៅតុលាការថ្នាក់ក្រោមថា អ្នកស្រីនឹងប្រគល់ប្រាក់ ៤៥ម៉ឺនដុល្លាអាមេរិក ប្រសិនបើលោក មខប្រគល់អាជ្ញាប័ណ្ណនាំឈើចេញមានតម្លៃប្រើប្រាស់តាមផ្លូវច្បាប់ ។

-យល់ឃើញថា លោកមខបានធ្វើសារណាការពាររឿងក្តីរបស់លោកជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះកំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថាៈ សាលដីការដ្ឋប្បវេណីលេខ ៧៤៨ ចុះថ្ងៃទី០៣-១២-៩៨ របស់សាលាឧទ្ធរណ៍ដែលបាន សម្រេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ចំពោះមុខអ្នកស្រីហស**

**កំបាំងមុខលោកមខប៉ុន្តែចាត់ទុកជាចំពោះមុខ**

១-ទទួលបណ្តឹងសាទុក្ខលេខ៤៣២ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៨ របស់អ្នកស្រីហសទុកជាត្រឹមត្រូវតាម ទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៧៤៨ចុះថ្ងៃទី០៣ខែធ្នូឆ្នាំ១៩៩៨របស់សាលាឧទ្ធរណ៍ទាំងមូល

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៣ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ១៩៩៩ របស់តុលាការកំពូលទៅសាលា ឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០៛ ដែលអ្នកស្រីហសបានបង់រួចហើយគឺៈ

-ពន្ធចុះបញ្ជី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីការកោះចំនួន ១៥០០០៛ សរុប ១៩០០០៛ ហើយតម្រូវឲ្យលោកមខសងប្រាក់ ចំនួន១៩០០០៛ នេះទៅអ្នកស្រីហសវិញ ។

៥-សាលដីកានេះជំនុំជំរះនៅថ្ងៃទី២៩ខែមិថុនាឆ្នាំ១៩៩៩ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ ។